ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 18

## ផលរបរ

## Revenue

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**”របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឲ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឲ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឲ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឲ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ចិ តាយី**

## គោលបំណង

ចំណូលត្រូវបានកំណត់នៅក្នុងក្របខណ្ឌ សម្រាប់ការរៀបចំ និងការបង្ហាញរបាយ-ការណ៍ហិរញ្ញវត្ថុ* ជាការកើនឡើងនៅក្នុង អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងកំឡុងការិយបរិច្ឆេទ គណនេយ្យនៅក្នុងទម្រង់នៃការហូរចូល ឬការកើនឡើង នៃទ្រព្យសកម្ម ឬការថយចុះនៃបំណុលដែលនាំឲ្យមានកើនឡើងនៅក្នុងដើមទុន ជាជាងការហូរចូលដែលទាក់ទង នឹងការដាក់ដើមទុនពីម្ចាស់មូលធន។ ចំណូលរួមបញ្ចូលទាំងផលរបរ និងចំណេញ។ ផលរបរ គឺជាចំណូល ដែលកើតចេញពីសកម្មភាពអាជីវកម្មធម្មតារបស់អង្គភាពមួយ និងត្រូវបានគេសំដៅដល់ឈ្មោះផ្សេងគ្នា រួមមានការលក់ ប្រាក់កំរៃការប្រាក់ ភាគលាភ និងសួយសារ ។ គោលបំណងនៃស្តង់ដានេះ គឺដើម្បីប្រាប់ពីការទទួលស្គាល់គណនេយ្យលើផលរបរ ដែលកើតឡើងពីប្រភេទប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់លាក់ ។

បញ្ហាចំបងនៅក្នុងគណនេយ្យសម្រាប់ផលរបរ គឺការកំណត់ពីពេលណាដែលត្រូវទទួល ស្គាល់ចំណូល។ ផលរបរត្រូវបានទទួលស្គាល់នៅពេលដែលវាទំនងថាអត្ថ ប្រយោជន៍សេដ្ឋកិច្ចនឹងហូរមកកាន់អង្គភាព និងអត្ថប្រយោជន៍ទាំងនេះអាចត្រូវ បានវាស់វែង ដោយជឿជាក់។ ស្តង់ដានេះកំណត់ពីហេតុការណ៍ដែលលក្ខណៈ វិនិច្ឆ័យទាំងនេះត្រឹមត្រូវនឹងត្រូវបានបំពេញ និងដូច្នេះហើយផលរបរត្រូវបាន ទទួលស្គាល់។ ស្តង់ដានេះក៏បានផ្តល់នូវ សេចក្តីណែនាំបែបអនុវត្តស្តីពីការប្រើប្រាស់ លក្ខណៈវិនិច្ឆ័យទាំងនេះ ។

១ ស្តង់ដានេះត្រូវបានប្រើនៅក្នុងគណនេយ្យសម្រាប់ផលរបរ ដែលកើតឡើងពីប្រតិបត្តិការនិងព្រឹត្តិការណ៍ខាងក្រោមៈ

(ក) ការលក់ទំនិញ

(ខ) ការផ្តល់សេវា និង

(គ) ការប្រើប្រាស់ទ្រព្យសកម្មរបស់អង្គភាពដោយអ្នកផ្សេងទៀត ដែលផ្តល់ជាចំណូលការប្រាក់ សួយសារ និង ភាគលាភ

២ ស្តង់ដានេះជំនួស ស.គ.អ.ក ១៨ *ការទទួលស្គាល់ផលរបរ* ដែលបានអនុម័តនៅក្នុង ១៩៨២ ។

៣ ទំនិញរួមមានទំនិញ ដែលបានផលិតដោយអង្គភាព សម្រាប់គោលបំណងលក់ និងទំនិញដែលបានទិញសម្រាប់លក់វិញ ដូចជា ទំនិញដែលបានទិញដោយអ្នកលក់រាយ ឬដី និងទ្រព្យផ្សេងទៀតដែលរក្សាទុកសម្រាប់លក់វិញ។

៤ ការផ្តល់សេវាជាសំខាន់ពាក់ព័ន្ធនឹង លទ្ធផលការងារដោយអង្គភាពលើការងារដែលបានព្រមព្រៀងតាមកិច្ច សន្យាលើការិយបរិច្ឆេទបានព្រមព្រៀងរួច។ សេវាអាចត្រូវបានផ្តល់ នៅក្នុងការិយបរិច្ឆេទទោល ឬលើសមួយការិយបរិច្ឆេទ។ កិច្ចសន្យាខ្លះសម្រាប់ការផ្តល់សេវាមានការពាក់ព័ន្ធផ្ទាល់ទៅនឹងកិច្ចសន្យាសាងសង់ ឧទាហរណ៍ កិច្ចសន្យាសម្រាប់សេវារបស់អ្នកគ្រប់គ្រងគំរោង និងស្ថាបត្យករគំរោង។ ផលរបរដែលកើត ឡើងពីកិច្ចសន្យាទាំងនេះ គឺមិនពាក់ព័ន្ធនឹងស្តង់ដានេះទេ ប៉ុន្តែមានការពាក់ព័ន្ធជាមួយនឹង ការតម្រូវសម្រាប់កិច្ចសន្យាសាងសង់ ដូចដែលបានបញ្ជាក់នៅក្នុង ស.គ.អ.ក ១១ *កិច្ចសន្យាសាងសង់* ។

៥ ការប្រើប្រាស់ទ្រព្យសកម្មរបស់អង្គភាពដោយអ្នកផ្សេងទៀត ផ្តល់ការកើនឡើងដល់ផលរបរនៅក្នុងទម្រង់នៃ:

(ក) ការប្រាក់ -កំរ៉ៃ សម្រាប់ការប្រើប្រាស់សាច់ប្រាក់ ឬសមមូលសាច់ប្រាក់ ឬទឹកប្រាក់ដែលហួសកំណត់ត្រូវ សងមកអង្គភាព

(ខ) សួយសារ -កំរ៉ៃ សម្រាប់ការប្រាក់ទ្រព្យសកម្មរយៈពេលវែងរបស់អង្គភាព ឧទាហរណ៍ ប្រកាសនីយប័ត្រ ផ្លាកសញ្ញាពាណិជ្ជកម្ម សិទ្ធិថតចម្លង និងផ្នែកទន់កុំព្យូទ័រ និង

(គ) ភាគលាភ- ការបែងចែកប្រាក់ចំណេញទៅឲ្យអ្នកកាន់ការវិនិយោគមូលធនតាមសមាមាត្រចំពោះការកាន់កាប់ថ្នាក់ដើមទុនជាក់លាក់

៦ ស្តង់ដានេះមិនជាប់ពាក់ព័ន្ធនឹងផលរបរដែលកើតឡើងពី:

(ក) កិច្ចព្រមព្រៀងភតិសន្យា (សូមមើល ស.គ.អ.ក ១៧ *ភតិសន្យា*)

(ខ) ភាគលាភ ដែលកើតឡើងពីការវិនិយោគ ដែលត្រូវបានធ្វើគណនេយ្យកម្មតាមវិធីសាស្រ្តមូលធន (សូមមើល ស.គ.អ.ក ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនសមាគត )*

(គ) កិច្ចសន្យាធានារ៉ាប់រងនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង*

(ឃ) ការប្រែប្រួលតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ឬការលក់ចោលនៃទ្រព្យសកម្ម និងបំណុលទាំងនោះ (សូមមើល ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ*)

(ង) ការប្រែប្រួលតម្លៃទ្រព្យសកម្មរយៈពេលខ្លីផ្សេងទៀត

(ច) ការទទួលស្គាល់លើកដំបូង និងការប្រែប្រួលតម្លៃសមស្របនៃ

ទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទងនឹងសកម្មភាពកសិកម្ម (សូមមើល ស.គ.អ.ក ៤១ *កសិកម្ម*)

(ឆ) ការទទួលយល់ស្គាល់លើកដំបូងនៃផលិតផលកសិកម្ម (សូមមើល ស.គ.អ.ក ៤១) និង

(ជ) ការទាញយករ៉ែ

## និយមន័យ

---

**៧ វាក្យស័ព្ទខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងអត្ថន័យដែលបានបញ្ជាក់ដូចតទៅៈ**

*ផលរបរ* **គឺជាលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងកំឡុងការិយបរិច្ឆេទដែលបានកើតឡើង នៅក្នុងសកម្មភាពធម្មតានៃអង្គភាពមួយ នៅពេលដែលលំហូរចូលទាំងនេះនាំឲ្យមានការកើនឡើង នៅក្នុងមូលធនជាជាងការកើនឡើងទាក់ទងនឹងការដាក់ដើមទុនពីម្ចាស់មូលធន ។**

*តម្លៃសមស្រប* **គឺជាទឹកប្រាក់ដែលទ្រព្យសកម្មមួយអាចត្រូវបានដោះដូរ ឬបំណុលត្រូវបានទូទាត់រវាងភាគី ដែលមានចំណេះដឹង និងស្ម័គ្រស្មោះនៅក្នុប្រតិបត្តិការបើកចំហ ។**

៨ ផលរបររួមបញ្ចូលតែលំហូរចូលដល់នៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលបានទទួលនិងត្រូវទទួលដោយអង្គភាព លើបញ្ជីផ្ទាល់របស់អង្គភាព។ ទឹកប្រាក់ដែលប្រមូលបានជំនួសភាគីទី៣ដូចជា ពន្ធលើការលក់ ពន្ធលើទំនិញនិងសេវា និងអាករលើតម្លៃបន្ថែម មិនមែនជាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលហូរចូលមកអង្គភាពទេ ហើយនិងមិនបាននាំឲ្យកើននៅក្នុងគណនីមូលធនទេ។ ដូច្នេះ ទឹកប្រាក់ទាំងនោះត្រូវដកចេញពី ផលរបរ។ ស្រដៀង

គ្នាដែរ នៅក្នុងទំនាក់ទំនងភ្នាក់ងារ លំហូរចូលដល់នៃអត្ថប្រយោជន៍សេដ្ឋកិច្ច រួមមានទឹកប្រាក់ដែលបានប្រមូលផ្តុំជំនួសឱ្យ Principal ហើយដែលមិននាំឱ្យកើនឡើងនៅក្នុងគណនីមូលធនសម្រាប់អង្គភាព ។ ទឹកប្រាក់ដែល ប្រមូលបានជំនួយឱ្យ Principal មិនមែនជាផលរបរទេ។ ជំនួយសមកវិញ ផលរបរគឺ ជាទឹកប្រាក់នៃកំរ៉ៃជើងសារ ។

## ការវាស់វែងចំណូល

**៩ ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬ ត្រូវទទួល***

១០ ទឹកប្រាក់ចំណូល ដែលកើតចេញ ពីប្រតិបត្តិការជាមួយជាធម្មតា ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាងអង្គភាព និងអ្នកទិញ ឬអ្នកប្រើប្រាស់នៃទ្រព្យសកម្ម។ វាត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬត្រូវបានទទួល ដោយត្រូវគិតពីតម្លៃនៃអបហារពាណិជ្ជកម្ម និងទំហំទឹកប្រាក់ទទួលបានមកវិញដែលបានអនុញ្ញាតិដោយអង្គភាព ។

១១ ករណីភាគច្រើន តម្លៃតបស្នងគឺស្ថិតនៅក្នុងទម្រង់នៃសាច់ប្រាក់ ឬសមមូល សាច់ប្រាក់និងទឹកប្រាក់នៃផលរបរ គឺជាទឹកប្រាក់នៃសាច់ប្រាក់ ឬសមមូល សាច់ប្រាក់ដែលបានទទួល ឬត្រូវទទួល ។ ប៉ុន្តែ នៅពេលដែលលំហូរចូល នៃសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ត្រូវបានពន្យាតម្លៃសមស្របនៃតម្លៃ តបស្នងអាចតិចជាង ទឹកប្រាក់មានតែនាមនៃសាច់ប្រាក់បានទទួល ឬត្រូវទទួល ។ ឧទាហរណ៍ អង្គភាពមួយអាចផ្តល់ឥណទានពុំមានការប្រាក់ទៅ ឱ្យអ្នកទិញ ឬទទួលយកប័ណ្ណត្រូវទទួលដែលមានអត្រាការប្រាក់ទាបជាង ទីផ្សារពីអ្នកទិញ ជាតម្លៃតបស្នង

សម្រាប់ការលក់ទំនិញ។ នៅពេលដែលការ រៀបចំបានបង្កើតឲ្យមានជាប្រតិបត្តិការហិរញ្ញប្បទាន នោះតម្លៃសមស្រប នៃតម្លៃតបស្នងត្រូវបានគណនា ដោយការធ្វើអប្បហារនូវទឹកប្រាក់ដែល ត្រូវទទួល នាពេលអនាគតទាំងអស់ដោយប្រើអត្រាការប្រាក់ ដែលដាក់ បន្ទុក។ អត្រាការប្រាក់ដែលដាក់បន្ទុកគឺអត្រា ដែលអាចកំណត់បានច្បាស់ ច្រើននៃះ

(ក) អត្រាធម្មតា សម្រាប់ឧបករណ៍ស្រដៀងគ្នា នៃក្រុមហ៊ុនបោះផ្សាយជាមួយនឹងការកម្រិតគុណភាពឥណទានឬ

(ខ) អត្រាការប្រាក់ដែលធ្វើអប្បហារទឹកប្រាក់មានតែនាមនៃ ឧបករណ៍ទៅជាតម្លៃលក់បច្ចុប្បន្នជាសាច់ប្រាក់ នៃទំនិញនិងសេវាភាពខុសគ្នារវាងតម្លៃសមស្របនៃទឹកប្រាក់មានតែនាមនៃតម្លៃតបស្នងត្រូវបានចាត់ទុកថាជាផលរបរការប្រាក់ដោយអនុលោមតាមកថាខ័ណ្ឌ ២៩ និង ៣០ និងដោយអនុលោមតាម ស.រ.ហ.អ.ក ៩ ។

១២ នៅពេលដែលទំនិញឬសេវាត្រូវបានដោះដូរ ឬផ្លាស់ប្តូរសម្រាប់ទំនិញ ឬសេវា ដែលមានលក្ខណៈនិងតម្លៃប្រហាក់ប្រហែលគ្នា ការដោះដូរមិនត្រូវបានចាត់ទុកជាប្រតិបត្តិការដែលបង្កើតផលរបរនោះទេ ។ នេះជារឿយៗជាករណីដែលកើតឡើងជាមួយនឹងទំនិញដូចជាប្រេង ឬទឹកដោះគោ ដែលអ្នកផ្គត់ផ្គង់ដោះដូរ ឬផ្លាស់ប្តូរសន្និធិនៅក្នុងទីតាំងផ្សេងគ្នា ដើម្បីបំពេញតម្រូវការតាមមូលដ្ឋានទាន់ពេលវេលា នៅក្នុងទីតាំងជាក់លាក់មួយ។ នៅពេលដែលទំនិញត្រូវបានលក់ ឬសេវាត្រូវបានផ្តល់ជាការដោះដូរសម្រាប់ទំនិញ ឬសេវា មិនស្រដៀងគ្នា ការដោះដូរត្រូវបានចាត់ទុកជាប្រតិបត្តិការដែលបង្កើតផលរបរ ។ ផលរបរត្រូវបានវាស់វែងតាម តម្លៃសមស្របនៃទំនិញ ឬសេវាដែលបានទទួលត្រូវបានកែសម្រួលដោយ ទឹកប្រាក់នៃសាច់

ប្រាក់ ឬសមមូលសាច់ប្រាក់ដែលបានផ្ទេរ។ នៅពេលដែលតម្លៃសមស្រប នៃទំនិញ ឬសេវា បានទទួលមិនអាចត្រូវបានវាស់ វែងដោយជឿជាក់ទេ នោះ ផលរបរត្រូវបានវាស់វែងតាមតម្លៃសមស្របនៃទំនិញ ឬសេវាដែលបានបោះបង់ ដោយការកែសម្រួលតាមទឹកប្រាក់នៃសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ដែលបានផ្ទេរ ។

## ការធ្វើអត្តសញ្ញាណកម្មលើប្រតិបត្តិការ

១៣ លក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់នៅក្នុងស្តង់ដានេះ ជាទូទៅត្រូវបានប្រើដាច់ដោយឡែកចំពោះប្រតិបត្តិការនីមួយៗ ។ ប៉ុន្តែ នៅក្នុងហេតុការណ៍ជាក់លាក់ គេចាំបាច់ត្រូវតែប្រើលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ចំពោះសមាសធាតុ អាចកំណត់បានដាច់ដោយឡែកនៃប្រតិបត្តិការទោលដើម្បីឆ្លុះបញ្ចាំង ពីស្ថានភាពពិតនៃប្រតិបត្តិការ ។ ឧទាហរណ៍ នៅពេលដែលថ្លៃលក់ផលិតផលរួមបញ្ចូលនូវ ទឹកប្រាក់អាចកំណត់បានសម្រាប់ ការផ្តល់សេវាកម្មបន្ទាប់ ទឹកប្រាក់នោះត្រូវបានពន្យានិងត្រូវបានទទួល ស្គាល់ជាផលរបរលើគ្រាក្នុង កំឡុងពេលដែលសេវាត្រូវបានអនុវត្ត ។ ផ្ទុយ មកវិញ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ត្រូ វបានប្រើ ចំពោះប្រតិ- បត្តិការពីរ ឬច្រើនរួមគ្នា នៅពេលដែលប្រតិបត្តិការនោះមានការពាក់ព័ន្ធ គ្នាតាមរបៀប ដែលឥទ្ធិពលផ្នែកពាណិជ្ជកម្មមិនអាចយល់បានដោយគ្មានសេចក្តីយោង ចំពោះប្រភេទប្រតិបត្តិការផ្សេងៗទាំងមូល ។ ឧទាហរណ៍ អង្គភាពមួយអាចលក់ទំនិញ និងនៅពេលជាមួយគ្នា ចុះកិច្ចព្រមព្រៀងដាច់ដោយឡែកដើម្បី ទិញត្រឡប់មកវិញនូវទំនិញនៅកាលបរិច្ឆេទពេលក្រោយ

ដូច្នេះ ការធ្វើឱ្យផ្ទុយនូវឥទ្ធិពលសំខាន់នៃប្រតិបត្តិការ នៅក្នុងករណីបែប នេះ ប្រតិបត្តិការទាំងពីរគឺមានការពាក់ព័ន្ធគ្នា ។

**ការលក់ទំនិញ**

---

**១៤ ផលរបរពីការលក់ទំនិញត្រូវបានទទួលស្គាល់នៅពេលដែលលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញៈ**

**(ក) អង្គភាពបានផ្ទេរទៅឱ្យអ្នកទិញនូវហានីភ័យនិងផលប្រយោជន៍សំខាន់ៗ នៃការកាន់កាប់ទំនិញ**

**(ខ) អង្គភាពមិនរក្សាការជាប់ពាក់ព័ន្ធនៃការគ្រប់គ្រងបន្តចំពោះកម្រិតមួយដែលមានការជាប់ពាក់ព័ន្ធនឹងការកាន់កាប់ និងមិនមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពលើទំនិញដែលបានលក់។**

**(គ) ទឹកប្រាក់ចំណូលអាចត្រូវបានវាស់វែងដោយជឿជាក់**

**(ឃ) វាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលជាប់ទាក់ទងនឹងប្រតិ-បត្តិការ នឹងហូរទៅកាន់អង្គភាព និង**

**(ង) ថ្លៃដើម ដែលបានកើតឡើង ឬនឹងកើតឡើងទាក់ទិននឹងប្រតិ-បត្តិការ អាចត្រូវបានវាស់វែង ដោយជឿជាក់**

១៥ ការវាយតម្លៃពីពេលវេលា ដែលអង្គភាពបានផ្ទេរនូវហានីភ័យ និងផលប្រយោជន៍សំខាន់ៗនៃការកាន់កាប់

ទៅអ្នកទិញតម្រូវឱ្យមានការត្រួតពិនិត្យ ពីហេតុការណ៍នៃប្រតិបត្តិការ ។ នៅក្នុងករណីភាគច្រើន ការផ្ទេរហានីភ័យ និងផលប្រយោជន៍ នៃការកាន់កាប់កើតឡើងដំណាលគ្នានឹងការផ្ទេរកម្មសិទ្ធិស្របច្បាប់ ឬការផ្ទេរការគ្រប់គ្រងទៅឱ្យអ្នកទិញ ។ នេះជាករណីសម្រាប់ ការលក់រាយភាគច្រើន ។ នៅក្នុងករណីផ្សេងទៀត ការផ្ទេរហានីភ័យ និង

ផលប្រយោជន៍នៃការកានកាប់កើតឡើងនៅពេលខុសគ្នាពីការផ្ទេរកម្មសិទ្ធិស្របច្បាប់ ឬ ផ្ទេរការកាន់កាប់ ។

១៦ ប្រសិនបើអង្គភាពរក្សាហានីភ័យសំខាន់ៗនៃការកាន់កាប់នោះប្រតិបត្តិការមិនមែនជាការលក់ទេ ហើយផលរបរ ក៏មិនត្រូវបានទទួលស្គាល់ដែរ។ អង្គភាពមួយ អាចរក្សាហានីភ័យនៃកម្មសិទ្ធិ នៅក្នុងរបៀបច្រើនយ៉ាង។ ឧទាហរណ៍ នៃស្ថានភាពដែលអង្គភាពអាចរក្សាហានីភ័យសំខាន់ៗ និង ផលប្រយោជន៍នៃការកាន់កាប់គឺ:

(ក) នៅពេលដែលអង្គភាពរក្សាកាតព្វកិច្ចសម្រាប់ការអនុវត្ត ដែលមិនពេញចិត្តដែលមិនមិនគ្របដណ្តប់ដោយសំវិធានធនលើការធានាធម្មតា

(ខ) នៅពេលដែល ការទទួលបានផលរបរពីការលក់ជាក់លាក់មួយមានលក្ខណៈយថាហេតុលើការទទួលបានផលរបរដោយអ្នកទិញពីការលក់ទំនិញ

(គ) នៅពេលដែល ទំនិញត្រូវបានដឹកជញ្ជូន ដែលជាកម្មវត្ថុនៃការតម្លើង ហើយការតម្លើងនោះគឺជាផ្នែក ចាំបាច់មួយនៃកិច្ចសន្យាដែលមិនទាន់បានបញ្ចប់ដោយអង្គភាព និង

(ឃ) នៅពេលដែល អ្នកទិញមានសិទ្ធិ ដើម្បីរំលាយចោលនូវការទិញដោយមានហេតុផលដូចបានបញ្ជាក់ នៅក្នុងកិច្ចសន្យាលក់ និង អង្គភាពមិនច្បាស់លាស់អំពីភវនីភាពនៃចំណូល ។

១៧ ប្រសិនបើ អង្គភាពមួយរក្សាតែហានីភ័យមិនសំខាន់នៃការកាន់កាប់ នោះ ប្រតិបត្តិការគឺជាការលក់ ហើយផលរបរត្រូវបានទទួលស្គាល់។ ឧទាហរណ៍ អ្នកលក់អាចរក្សាហានីភ័យ និងផលរប្រយោជន៍សំខាន់ៗនៃការកាន់កាប់

អាចជាការលក់រាយ នៅពេលដែលការបង្វិលសងវិញ ត្រូវបានផ្តល់ឲ្យ ប្រសិនបើអតិថិជនមិនពេញចិត្ត។ ផលរបរនៅក្នុងករណីបែបនេះត្រូវបាន ទទួលស្គាល់នៅពេលដែលការលក់បានផ្តល់ឲ្យអ្នកលក់ អាចត្រូវបានប៉ាន់ ស្មានដោយជឿជាក់ពីចំណូលនាពេលអនាគត និងទទួលស្គាល់ជាបំណុល សម្រាប់ចំណូល ដែលផ្អែកលើបទពិសោធន៍អតីតកាល និងកត្តាទាក់ទិន ផ្សេងទៀត ។

១៨ ផលរបរត្រូវបានទទួលស្គាល់ តែនៅពេលដែលវាទំនងថាអត្ថប្រយោជន៍ សេដ្ឋកិច្ចដែលជាប់ទាក់ទងនិងប្រតិបត្តិការហូរមកកាន់អង្គភាព។ នៅក្នុង ករណីមួយចំនួន នេះជាមិនមានភវនីយទេរហូតដល់តម្លៃតបស្នងត្រូវបាន ទទួល ឬរហូតដល់ភាពមិនប្រាកដប្រជាត្រូវបានដកចេញ។ ឧទាហរណ៍ វាអាចមិនប្រាកដថាអាជ្ញាធររដ្ឋាភិបាលក្រៅប្រទេស នឹងផ្តល់ការអនុញ្ញាតិ ដើម្បីទទួលតម្លៃតបស្នងពីការលក់នៅក្នុងប្រទេសក្រៅដែរ ឬអត់។ នៅ ពេលដែលការអនុញ្ញាតិត្រូវបានផ្តល់ឲ្យ នោះភាពមិនប្រាកដប្រជាត្រូវបាន ដកចេញ ហើយផលរបរត្រូវបានទទួលស្គាល់ ។ ប៉ុន្តែ នៅពេលដែលភាព មិនប្រាកដប្រជាកើតឡើង អំពីភាពអាចប្រមូលនៃទឹកប្រាក់ ដែលបាន បញ្ចូលរួចហើយនៅក្នុងផលរបរ នោះទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬទឹកប្រាក់ទាក់ទិន នឹងទទួលបានមកវិញលែងមានភវនីយតទៅទៀតត្រូវ បានទទួលស្គាល់ជាចំណាយ ជាជាងការធ្វើនិយ័តភាព ទឹកប្រាក់ផលរបរ ដែលទទួលស្គាល់លើកដំបូងរួចហើយ ។

១៩ ផលរបរ និងចំណាយ ដែលទាក់ទិននឹងប្រតិបត្តិការដូចគ្នា ឬព្រឹត្តិការណ៍ ផ្សេងៗត្រូវបានទទួលស្គាល់ស្របពេលគ្នា ដំណើរការនេះជារួមត្រូវបាន ហៅថា ការផ្គូរផ្គងផលរបរនិងចំណាយ ។ ចំណាយ ដែលរួមមានការធានា

និង ថ្លៃដើមផ្សេងទៀតដែលនឹងកើតឡើងបន្ទាប់ពីការដឹកជញ្ជូនទំនិញជាធម្មតាអាចត្រូវបានវាស់វែងដោយជឿជាក់ នៅពេលដែលលក្ខខណ្ឌផ្សេងទៀត សម្រាប់ការទទួលស្គាល់ផលរបរត្រូវបានបំពេញ ។ ប៉ុន្តែផលរបរមិនអាចត្រូវបានទទួលស្គាល់នៅពេលដែលចំណាយមិនអាចត្រូវបានវាស់វែងដោយជឿជាក់ នៅក្នុងហេតុការណ៍បែបនេះ តម្លៃតបស្នងណាដែលបានទទួលស្គាល់រួចហើយសម្រាប់ការលក់ទំនិញ ត្រូវបានទទួលស្គាល់ជាបំណុល។

## ការផ្តល់សេវាកម្ម

២០ នៅពេលដែលលទ្ធផលនៃប្រតិបត្តិការដែលទាក់ទិននឹងការផ្តល់សេវាអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ ផលរបរដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយយោងតាមដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនៅចុងការិយបរិច្ឆេទរាយការណ៍ ។ លទ្ធផលនៃប្រតិបត្តិការអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់នៅ ពេលដែលលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញៈ

(ក) ទឹកប្រាក់នៃផលរបរអាចត្រូវបានវាស់វែងបាន

(ខ) វាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងប្រតិបត្តិការនឹងហូរមកកាន់អង្គភាព

(គ) ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនៅចុងការិល័យបរិច្ឆេទរាយការណ៍ អាចត្រូវបានវាស់វែងដោយជឿជាក់ និង

(ឃ) ថ្លៃដើមដែលបានកើតឡើងសម្រាប់ប្រតិបត្តិការ និងថ្លៃដើមដើម្បីបញ្ចប់ប្រតិបត្តិការអាចត្រូវបាន វាស់វែងដោយជឿជាក់

២១ ការទទួលស្គាល់ផលរបរដោយយោងដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការជាទូទៅត្រូវបានសំដៅលើជាភាគរយនៃវិធីសាស្ត្របញ្ចប់ការងារ ។ ក្រោមវិធីសាស្ត្រនេះ ផលរបរត្រូវបានទទួលស្គាល់នៅក្នុង ការិយបរិច្ឆេទគណនេយ្យដែលសេវាត្រូវបានផ្តល់។ ស.គ.អ.ក ១១ ក៏បានតម្រូវឲ្យមានផងដែរ នូវការទទួលស្គាល់ ផលរបរតាមមូលដ្ឋាននេះ។ ការតម្រូវនៃស្តង់ដានោះ ជាទូទៅអាចអនុវត្តបានចំពោះការទទួលស្គាល់ផលរបរនិងចំណាយពាក់ ព័ន្ធសម្រាប់ប្រតិបត្តិការដែលទាក់ទិននឹងការផ្តល់សេវា ។

២២ ផលរបរត្រូវបានទទួលស្គាល់ តែនៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងប្រតិបត្តិការនឹងហូរមកអង្គភាព។ ប៉ុន្តែ នៅពេលដែលភាពមិនប្រាកដប្រជាកើតឡើង អំពីភាពអាចប្រមូលបាននៃទឹកប្រាក់ ដែលបានបញ្ចូលនៅក្នុងផលរបររួចហើយ ទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬទឹកប្រាក់ដែល ទាក់ទិននឹងការទទួលបានមកវិញលែងមានភវនីយភាព ត្រូវបានទទួលស្គាល់ជាចំណាយ ជាជាងការធ្វើនិយ័តភាពនៃទឹកប្រាក់ផលរបរដែលបានទទួលស្គាល់លើកដំបូង ។

២៣ អង្គភាពមួយ ជាទូទៅអាចធ្វើការប៉ាន់ស្មានដែលអាចជឿជាក់បានបន្ទាប់ពីអង្គភាពបានយល់ព្រមចំពោះលក្ខខណ្ឌ ដូចខាងក្រោម ជាមួយភាគីផ្សេងទៀតចំពោះប្រតិបត្តិការៈ

(ក) សិទ្ធិអនុវត្តរបស់ភាគីនីមួយៗទាក់ទិននឹងសេវាត្រូវផ្តល់ឲ្យនិងត្រូវទទួលដោយភាគីទាំងអស់

(ខ) តម្លៃតបស្នងដែលត្រូវដោះដូរ និង

(គ) ឥរិយាបទនិងលក្ខខណ្ឌនៃការទូទាត់ ។

វាក៏មានភាពចាំបាច់ផងដែរសម្រាប់អង្គភាពដើម្បីមានប្រព័ន្ធរាយការណ៍

និង ប្រព័ន្ធធ្វើគំរោងហិរញ្ញវត្ថុផ្ទៃក្នុង ដែលមានប្រសិទ្ធិភាព ។ អង្គភាពពិនិត្យ ឡើងវិញនិងពេលចាំបាច់ត្រូវកែប្រែការប៉ាន់ស្មានពីផលរបរ នៅពេលសេវា ត្រូវបានបំពេញ ។ សេចក្ដីត្រូវការសម្រាប់ការ កែប្រែបែប នេះ មិនចាំបាច់ បង្ហាញថាលទ្ធផលនៃប្រតិបត្តិការ មិនអាចត្រូវ បានប៉ាន់ស្មានដោយជឿ ជាក់។

២៤ ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការអាចត្រូវបានកំណត់ដោយវិធីសាស្ត្រ ច្រើនយ៉ាង ។ អង្គភាពមួយប្រើវិធីសាស្ត្រ ដែលវាសវែងដោយជឿជាក់ពី សេវាដែលបានអនុវត្ត ។ ដោយផ្អែកលើលក្ខណៈប្រតិបត្តិការ វិធីសាស្ត្រ ទាំងនោះអាចមានៈ

(ក) ការស្ទាបស្ទង់ពីការងារបានអនុវត្តរួច

(ខ) សេវាបានបំពេញត្រឹមថ្ងៃបិទបញ្ជីជាភាគរយនៃសេវាសរុប ដែល ត្រូវបំពេញ ឬ

(គ) សមាមាត្រដែលថ្លៃដើមបានកើតឡើងត្រឹមថ្ងៃបិទបញ្ជីធៀបនឹងថ្លៃ ដើមសរុបប៉ាន់ស្មាន នៃប្រតិបត្តិការ។ មានតែថ្លៃដើមដែលឆ្លុះ បញ្ចាំងពីសេវាបានអនុវត្តត្រឹមថ្ងៃបិទបញ្ជីទេត្រូវបានបញ្ចូលក្នុងថ្លៃ ដើម ដែលបានកើតឡើងត្រឹមថ្ងៃបិទបញ្ជី ។ មានតែថ្លៃដែលឆ្លុះ បញ្ចាំងពីសេវាដែលបានអនុវត្ត ឬត្រូវអនុវត្តតែត្រូវបានបញ្ចូលនៅ ក្នុងថ្លៃសរុបប៉ាន់ស្មាននៃប្រតិបត្តិការ ។

ការទូទាត់កំពុងដំណើរការ និងប្រាក់បុរេប្រទានដែលបានទទួលពីអតិថិជន ជារឿយៗមិនបានឆ្លុះបញ្ចាំងពី សេវាដែលបានបំពេញ ។

២៥ សម្រាប់គោលបំណងអនុវត្ត នៅពេលដែលសេវាត្រូវបានអនុវត្តដោយចំនួន

សកម្មភាពមិនច្បាស់លាស់លើ រយៈពេលនៃកាវិយបរិច្ឆេទបានបញ្ចាក់នោះ ផលរបរត្រូវបានទទួលស្គាល់តាមមូលដ្ឋានថេរលើកាវិយបរិច្ឆេទជាក់លាក់ លុះត្រាតែមានភស្តុងតាងថាវិធីសាស្ត្រមួយចំនួនទៀតតំណាងឲ្យដំណាក់កាលនៃការបញ្ចប់ការងារល្អប្រសើរជាង។ នៅពេលដែលសកម្មភាពជាក់លាក់មួយមានលក្ខណៈសំខាន់ច្រើនជាងសកម្មភាពដទៃផ្សេងទៀត នោះការទទួលស្គាល់នៃផលរបរត្រូវបានពន្យារហូតដល់សកម្មភាពសំខាន់នោះត្រូវបាន អនុវត្ត។

២៦ **នៅពេលដែលលទ្ធផលនៃប្រតិបត្តិការដែលទាក់ទិននឹងការផ្តល់សេវាមិនអាចត្រូវបានប៉ាន់ស្មាន ដោយជឿជាក់ផលរបរត្រូវបានទទួលស្គាល់ក្នុងទំហំនៃចំណាយដែលបានទទួលស្គាល់ដែលអាចទទួល បានមកវិញ។**

២៧ ក្នុងកំឡុងដំណាក់កាលដំបូងនៃប្រតិបត្តិការ វាតែងតែមានកើតមានជាករណីដែលថាលទ្ធផលនៃប្រតិបត្តិការ មិនអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ ។ តែទោះបីជាយ៉ាងណាក៏ដោយវាអាចទំនងថាអង្គភាពនឹងទទួលបានមកវិញនូវថ្លៃដើមប្រតិបត្តិការដែលបានកើតឡើង ។ ដូច្នេះផលរបរត្រូវ បានទទួលស្គាល់តែក្នុងទំហំថ្លៃ ដើមដែលបានកើតឡើងដែលត្រូវបានរំពឹងថាអាចទទួលបានមកវិញ ។ ខណៈពេលដែលលទ្ធផលនៃប្រតិបត្តិការនៃប្រតិបត្តិការមិនអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ពុំមានប្រាក់ចំណេញណាមួយត្រូវបានទទួលស្គាល់នោះទេ ។

២៨ នៅពេលដែលលទ្ធផលនៃប្រតិបត្តិការមិនអាចត្រូវបានប៉ាន់ស្មាន ដោយជឿជាក់ និងមិនទំនងថាថ្លៃដើមដែលបានកើតឡើងនឹងអាចទទួលបានវិញនោះផលរបរមិនត្រូវបានទទួលស្គាល់ ហើយថ្លៃដើមដែលបានកើតឡើងត្រូវបានទទួលស្គាល់ជាចំណាយ ។ នៅពេលដែលភាពមិនប្រាកដប្រជា

ដែលបានការពារលើលទ្ធផលនៃកិច្ចសន្យា ដែលកំពុងត្រូវបានប៉ាន់ស្មាន ដោយជឿជាក់មិនកើតមានតទៅទៀត នោះផលរបរត្រូវបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ២០ ជាជាងអនុលោមតាមកថាខណ្ឌ ២៦ ។

## ការប្រាក់ សួយសារ និង ភាគលាភ

២៩ ផលរបរដែលកើតឡើងពីការប្រើប្រាស់ទ្រព្យសកម្មរបស់អង្គភាពដោយអ្នកផ្សេងទៀត ដែលផ្តល់ផលជាការប្រាក់ ភាគលាភត្រូវបានទទួលស្គាល់តាមមូលដ្ឋានដែលបានកំណត់នៅក្នុងកថាខណ្ឌ ៣០ នៅពេលៈ

(ក) វាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលជាប់ទាក់ទងនឹងប្រតិបត្តិការនឹងហូរមកកាន់អង្គភាព និង

(ខ) ទឹកប្រាក់នៃផលរបរអាចត្រូវបានវាស់វែងដោយជឿជាក់ ។

៣០ ផលរបរត្រូវបានទទួលស្គាល់តាមមូលដ្ឋានដូចខាងក្រោមៈ

(ក) ការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពដូចបានកំណត់នៅក្នុង ស.គ.អ.ក ៣៩ កថាខណ្ឌ ៩ និង កឆ-កឆ៨

(ខ) សួយសារត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ដោយអនុលោមតាមស្ថានភាពពិតនៃកិច្ច ព្រមព្រៀង ទាក់ទិន និង

(គ) ភាគលាភត្រូវបានទទួលស្គាល់នៅពេលដែលសិទ្ធិរបស់ម្ចាស់ភាគហ៊ុនត្រូវទទួលត្រូវបានបង្កើតឡើង ។

៣១ [លុបចោល]

៣២ នៅពេលដែល ការប្រាក់មិនទាន់បានបង់បានបង្គរទុក នៅពេលការទិញយកការវិនិយោគមានការប្រាក់ នោះការទទួលបានការប្រាក់ត្រូវបានបែងចែករវាងការិយបរិច្ឆេទមុនការទិញ និងការិយបរិច្ឆេទក្រោយការទិញមានតែចំណែកក្រោយការទិញប៉ុណ្ណោះត្រូវបានទទួលស្គាល់ជាផលរបរ ។

៣៣ ស្វ័យសារបង្គរទុកដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទាក់ទិន និងជាទូទៅត្រូវបានទទួលស្គាល់តាមមូលដ្ឋាននោះ ដោយមានការពាក់ព័ន្ធនឹងស្ថានភាពពិតនៃកិច្ចព្រមព្រៀង វាមានភាពសមស្របជាង ដើម្បីទទួលស្គាល់ផលរបរតាមមូលដ្ឋានជាប្រព័ន្ធនិងសមហេតុផលដទៃសផ្សេងទៀត។

៣៤ ផលរបរត្រូវបានទទួលស្គាល់ តែនៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចទាក់ទិននឹងប្រតិបត្តិការនឹងហូរមកកាន់អង្គភាព។ ប៉ុន្តែ នៅពេលដែលភាពមិនប្រាកដប្រជាកើតឡើង អំពីភាពអាចប្រមូលបាននៃទឹកប្រាក់ដែលបានបញ្ចូលក្នុងផលរបររួចហើយ នោះចំនួនទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬទឹកប្រាក់ដែល ទាក់ទិននឹងការទទួលបានមកវិញលែងមានភវនីយតទៅទៀត ត្រូវបានទទួលស្គាល់ជាចំណាយជាជាងការ កែសម្រួលនៃទឹកប្រាក់ផលរបរដែលទទួលស្គាល់លើកដំបូង។

## ការលាតត្រដាង

---

**៣៥ អង្គភាពត្រូវលាតត្រដាងៈ**

**(ក)**

គោលនយោបាយគណនេយ្យដែលបានប្រើសម្រាប់ការទទួលស្គាល់ ផលរបរ រួមបញ្ចូលវិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការដែលទាក់ទិននឹងការផ្តល់សេវា

(ខ) ទឹកប្រាក់នៃខ្ទង់សំខាន់នីមួយៗនៃផលរបរ ដែលបានទទួលស្គាល់ក្នុងកំឡុងការិយបរិច្ឆេទ រួមបញ្ចូល ទាំងផលរបរដែលកើតចេញពីៈ

(១) ការលក់ទំនិញ

(២) ការផ្តល់សេវា

(៣) ការប្រាក់

(៤) សួយសារ

(៥) ភាគលាភ និង

(គ) ទឹកប្រាក់ផលរបរដែលកើតចេញពីការដោះដូរទំនិញ ឬសេវារួមបញ្ចូលនៅក្នុងខ្ទង់សំខាន់នីមួយៗ នៃផលរបរ ។

៣៦ អង្គភាពមួយលាតត្រដាងពីបំណុលយថាហេតុ និងទ្រព្យយថាហេតុដោយអនុលោមតាម ស.គ.អ.ក ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យយថាហេតុ។* បំណុលយថាហេតុនិងទ្រព្យសកម្មយថាហេតុអាច កើតចេញពីធាតុដូចជា ថ្លៃដើមលើការធានា ការទាមទារពិន័យ ឬការខាត ដែលអាចកើតមាន ។

៣៧ ស្តង់ដានេះអនុវត្ត សម្រាប់របាយការណ៍ហិរញ្ញវត្ថុ ដែលគ្របដណ្តប់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ១៩៩៥ ។

៣៨ *ថ្លៃដើមនៃការវិនិយោគ នៅក្នុងក្រុមបុត្រសម្ព័ន្ធ អង្គភាពគ្រប់គ្រងរួម ឬសមាគត* (វិសោធនកម្ម ចំពោះ ស.រ.ហ.អ.ក ១ *ការអនុវត្តជាលើកដំបូងនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* និង ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុរួមនិងដាច់ដោយឡែក)* ដែលបាបោះផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨ បានកែប្រែកថាខណ្ឌ ៣២ ។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទៅពេលខាងមុខ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដោយចាំផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ។ ការអនុវត្តមុនត្រូវបាន អនុញ្ញាតិ ។ ប្រសិនបើ អង្គភាពមួយ ប្រើវិសោធនកម្មទាក់ទិននៅក្នុងកថា ខណ្ឌ ៤ និង ៣៨ក នៃ ស.គ.អ.ក ២៧ សម្រាប់គ្រាមុន អង្គភាពត្រូវប្រើ វិសោធនកម្មនៅក្នុងកថាខណ្ឌ៣២ នៅពេលជាមួយគ្នាដែរ ។

៣៩ [លុបចោល]

៤០ ស.រ.ហ.អ.ក ៩ ដែលបានបោះផ្សាយនៅក្នុង ខែតុលា ឆ្នាំ២០១០ បានវិសោធនកម្មកថាខណ្ឌ ៦ (ឃ) និង ១១ និងកថាខណ្ឌ ៣៩ ដែលបានលុបចោល ។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទាំងនោះ នៅពេលដែលអង្គភាពប្រើ ស.រ.ហ.អ.ក ៩ ដែលបានចេញផ្សាយ នៅក្នុងខែតុលាឆ្នាំ២០១០ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ